ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤២៥
ចុះថ្ងៃទី០៧-៥-២០១៣

សាលដីកា
លេខ: ៦៩ ក្រ VI ញ
ចុះថ្ងៃទី២០-១០-២០១៤

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ តាម ព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី៣០-៩-២០១៤ ម៉ោង ៨:០០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:៤២៥ចុះថ្ងៃទី០៧-៥-២០១៣របស់សាលាឧទ្ធរណ៍ ដែលមាន:

**-ជនជាប់ចោទ:**

១-ឈ្មោះ [redacted] ស្រីស ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបររត់គុ កើតនៅភូមិ [redacted] សព្វថ្ងៃស្នាក់នៅផ្ទះជួល [redacted] ប្តីឈ្មោះ [redacted] "រ" មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

២-ឈ្មោះ [redacted] ស្រីជា ហៅ តាព ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបររត់គុ កើតនៅ [redacted] សព្វថ្ងៃស្នាក់នៅផ្ទះ [redacted] ប្តីឈ្មោះ [redacted] "រ" មានកូន០១នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

-មានលោកស្រី [redacted] ទិមានចំប៉ា ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ស្រីស និងឈ្មោះ [redacted] ស្រីជា ។

ជាប់ចោទពីបទៈ **សញ្ចារកម្មមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខភោជនីយដ្ឋានសេងលីប ផ្លូវព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩-៩-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨៨នៃក្រមព្រហ្មទណ្ឌ។

-<u>ដើមបណ្តឹងរដ្ឋប្បវេណីៈ</u>

១-ឈ្មោះ [redacted] **ផល្លា** ភេទស្រី អាយុ២៧ឆ្នាំ មានទីលំនៅភូមិ [redacted]។

២-ជនរងគ្រោះឈ្មោះ [redacted] **ស្រីពៅ** ភេទស្រី អាយុ១៧ឆ្នាំ មានទីលំនៅភូមិ [redacted]។

៣-ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ [redacted] **ស្រីព្រឹង** ហៅ **អ៊ីង** ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅផ្ទះលេខៈ [redacted]។

-មានលោក [redacted] **ណារ៉ា** និងលោក [redacted] **ស៊ីថាន់** ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផល្លា** ។

## <u>ឯរឿងហេតុមានដូចតទៅ</u>

នៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១២ មានភ្ញៀវម្នាក់មិនស្គាល់ឈ្មោះ បានទាក់ទងឈ្មោះ [redacted] ស្រីដា ហៅ ភាព ឲ្យរកក្មេងស្រីក្រមុំចំនួនពីរនាក់ សម្រាប់គេយកទៅរួមភេទ ភ្ញៀវនោះមានលេខទូរស័ព្ទ ០៩៩ ៨៦៦៦៦៣។ បន្ទាប់មកឈ្មោះ [redacted] ស្រីដា ក៏បានទាក់ទងទៅឈ្មោះ [redacted] ស្រីស ដែលជាអ្នករួមការងារជាមួយគ្នា ហើយឈ្មោះ [redacted] ស្រីដា បានផ្តល់ពត៌មានទៅភ្ញៀវវិញថា ខ្លួនមានស្រីក្រមុំព្រហ្មចារីយ៍ចំនួនពីរនាក់ក្នុងម្នាក់តម្លៃ១០០០ដុល្លាអាមេរិក ពេលនោះភ្ញៀវក៏យល់ព្រម ហើយក៏បានណាត់ជួបជាមួយឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស្រីស ដើម្បីពិនិត្យមើលក្មេងស្រីទាំងពីរនោះ ក្រោយពីបានឃើញ ភ្ញៀវក៏ពេញចិត្ត ហើយបានប្រគល់ប្រាក់ចំនួន១០០$ ទៅឲ្យឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស្រីស ដើម្បីឲ្យយកក្មេងស្រីទាំងពីរនាក់ទៅពិនិត្យឈាម។ ក្មេងស្រីទី១ឈ្មោះ [redacted] ស្រីពីង អាយុ២២ឆ្នាំ និងក្មេងស្រីទី២ ឈ្មោះ [redacted] ស្រីពៅ អាយុ១៧ឆ្នាំ នៅថ្ងៃទី២៩-៩-២០១២ វេលាម៉ោង២រសៀល ឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស្រីស បាននាំក្មេងស្រីទាំងពីរនាក់ទៅប្រគល់ឲ្យភ្ញៀវនៅភោជនីយដ្ឋានមួយ នៅទល់មុខមន្ទីរពេទ្យកាល់ម៉ែត្រ ក៏ត្រូវសមត្ថកិច្ចឃាត់ចាប់ខ្លួនតែម្តង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ៨១"ក្រ.១.គ" ចុះថ្ងៃទី០២-៤-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោមៈ

១-ប្តូរបទបញ្ញត្តិនៃការចោទប្រកាន់លើឈ្មោះ [redacted] **ស្រីស** ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **ស្រីដា** ហៅ **ភាព** ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ពីបទៈ សញ្ចារកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខភោជនីយដ្ឋានសេងលីប ផ្លូវព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩-៩-២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨៨ នៃក្រមព្រហ្មទណ្ឌ មកបទ សញ្ចារកម្មមានស្ថានទម្ងន់ទោសទាក់ទង

ទៅនឹងជនរងគ្រោះ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨៩ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាវិញ ។

២-ផ្តន្ទាទោស:

ក-ឈ្មោះ [redacted] ស្រីស ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបររត់គុ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះ [redacted] ប្តីឈ្មោះ [redacted] "រ" មានកូន០១នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ជានីតិជន

ខ-ឈ្មោះ [redacted] ស្រីដា ហៅ ភាព ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបររត់គុ ទីកន្លែង [redacted] ទីលំនៅបច្ចុប្បន្នផ្ទះ [redacted] ប្តីឈ្មោះ [redacted] "រ" មានកូន០១នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ជានីតិជន

ដាក់ពន្ធនាគារម្នាក់ៗកំណត់០៥ឆ្នាំ(ប្រាំឆ្នាំ) ពីបទ: សញ្ជារកម្មមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ដែលកើតមានឡើងនៅចំណុចមុខភោជនីយដ្ឋាន សេងលីប ផ្លូវព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩-៩-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨៩, ៩៣, ៩៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីស នឹងជនជាប់ចោទឈ្មោះ [redacted] ស្រីដា ហៅ ភាព រួមគ្នាសងសំណងជម្ងឺចិត្តក្នុងម្នាក់ៗ ចំនួន១.០០០.០០០រៀល(មួយលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] ហៅ អ៊ីង ម្នាក់ៗចំនួន ១.០០០.០០០៛(មួយលានរៀល) ការទាមទារលើសពីនេះបដិសេធចោល ។

៤-វត្ថុចាប់យករួមមាន:

ក-ទូរស័ព្ទដៃម៉ាណូគា១២០២ មួយគ្រឿង(ចាស់)

ខ-ទូរស័ព្ទដៃផលិតនៅប្រទេសចិន មួយគ្រឿង(ចាស់)

ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

៥-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីស, ឈ្មោះ [redacted] ស្រីដា ហៅ ភាព, មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted], ឈ្មោះ [redacted] ហៅ អ៊ីង, ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ, មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ និងប្រកាសជាសាធារណៈថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី២០-៦-២០១៣។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី១៤-៨-២០១៣។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ស្រីស (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ស្រីដា ១០៧ (វត្តមាន)

-មេធាវី [redacted] ទិមានចំប៉ា (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា (វត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ (វត្តមាន)

-មេធាវី [redacted] ណារ៉ា (វត្តមាន)

-មេធាវី [redacted] ស៊ីថាន់ (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ស្រីស បានឆ្លើយថា: ខ្លួននៅពេលនេះ ទទួលស្គាល់នូវអំពើ ដែលខ្លួនបានប្រព្រឹត្ត តែខ្លួនប្ដឹងឧទ្ធរណ៍ដោយហេតុថា សាលាដំបូងបានសម្រេចដាក់ទោសខ្លួនធ្ងន់ធ្ងរពេក។ ខ្លួនស្គាល់ជនរងគ្រោះ តាមរយៈខ្លួនជួលផ្ទះស្នាក់នៅ។ នៅពេលនេះ ខ្លួនសំណូមពរសុំសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] ស្រីដា បានឆ្លើយថា: ខ្លួននៅពេលនេះ ទទួលស្គាល់នូវអំពើ ដែលខ្លួនបានប្រព្រឹត្ត តែខ្លួនប្ដឹងឧទ្ធរណ៍ដោយហេតុថា សាលាដំបូងបានសម្រេចដាក់ទោសខ្លួនធ្ងន់ធ្ងរពេក។ ខ្លួនស្គាល់ភៀវ ខ្លួនអត់ដឹងថា គាត់ធ្វើអ្វីទេ គាត់អត់ដែលបានឲ្យលុយខ្លួនម្ដងណាទេ។ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនតាមច្បាប់ ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា បានឆ្លើយថា: នៅពេលនេះ ខ្លួនសុំប្រគល់សិទ្ធិជូនមេធាវីឆ្លើយជំនួស ។

**<u>តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា</u>**

រឿងនេះ ជនជាប់ចោទបានឆ្លើយទទួលស្គាល់នូវអំពើប្រព្រឹត្តអស់ហើយ។ ដូចនេះសុំលោកចៅក្រម តម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការតាមច្បាប់ ។

-មេធាវី [redacted] ណារ៉ា បានធ្វើសេចក្ដីសន្និដ្ឋានថា: ជនជាប់ចោទនៅពេលនេះ បានឆ្លើយទទួលស្គាល់នូវអំពើប្រព្រឹត្តអស់ហើយ។ នៅពេលនេះ ខ្លួនសំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល ។

-មេធាវី [redacted] ស៊ីថាន់ បានធ្វើសេចក្ដីសន្និដ្ឋានថា: នៅពេលនេះ ខ្លួនសុំឯកភាពតាមការបញ្ជាក់របស់មេធាវី ជា ណារ៉ា ទាំងស្រុង ។

-មេធាវី [redacted] ទិមានចំប៉ា បានធ្វើសេចក្ដីសន្និដ្ឋានថា: នៅពេលសវនាការនេះ កូនក្ដីខ្លួនបានឆ្លើយសារភាពអស់ហើយ។ ក៏ប៉ុន្តែខ្លួនសុំបញ្ជាក់ថា កូនក្ដីខ្លួនអត់បានបង្ខិតបង្ខំជនរងគ្រោះអ្វីឡើយ គឺជនរងគ្រោះគាត់ស្មោះស្ម័គ្រ ដោយខ្លួនឯង។ ម្យ៉ាងវិញទៀត អំពើដែលកូនក្ដីខ្លួន ប្រព្រឹត្តនោះ គឺកូនក្ដីខ្លួនអត់បានយល់ដឹងថា ខុសច្បាប់ រឺយ៉ាងណានោះទេ។ ដូច្នេះ នៅពេលនេះខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍មេត្តា បន្ធូរបន្ថយទោសឲ្យកូនក្ដីខ្លួនតាមច្បាប់ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ✓-

# សាលាឧទ្ធរណ៍
# យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-៤-២០១៣ របស់ឈ្មោះ [redacted] ស្រីដា និងឈ្មោះ [redacted] ស្រីស ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] ស្រីស បានឆ្លើយសារភាពថា: ខ្លួននៅពេលនេះទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្ត តែខ្លួនប្ដឹងឧទ្ធរណ៍ដោយហេតុថា សាលាដំបូងបានសម្រេចដាក់ទោសខ្លួនធ្ងន់ធ្ងរពេក។ ខ្លួនស្គាល់ជនរងគ្រោះ តាមរយៈខ្លួនជួលផ្ទះស្នាក់នៅ។ នៅពេលនេះខ្លួនសំណូមពរសុំ សាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនតាមច្បាប់ ។

៣-ជនជាប់ចោទឈ្មោះ [redacted] ស្រីដា បានឆ្លើយសារភាពថា: ខ្លួននៅពេលនេះ ទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្ត តែខ្លួនប្ដឹងឧទ្ធរណ៍ដោយហេតុថា សាលាដំបូងបានសម្រេចដាក់ទោសខ្លួនធ្ងន់ធ្ងរពេក។ ខ្លួនស្គាល់ភ្ញៀវ ខ្លួនអត់ដឹងថាគាត់ធ្វើអ្វីទេ គាត់អត់ដែលបានឲ្យលុយខ្លួនម្ដងណាទេ។ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនតាមច្បាប់ ។

៤-ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា បានឆ្លើយថា: នៅពេលនេះ ខ្លួនសុំប្រគល់សិទ្ធិជូនមេធាវីឆ្លើយជំនួស ។

៥-មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការឃាត់ខ្លួនជនជាប់ចោទក្នុងករណីបទល្មើសជាក់ស្ដែង ។

៦-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: រឿងនេះ ជនជាប់ចោទបានឆ្លើយទទួលស្គាល់នូវអំពើប្រព្រឹត្តអស់ហើយ។ ដូចនេះសុំលោកចៅក្រម តម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការតាមច្បាប់ ។

៧-មេធាវី [redacted] ណារ៉ា ការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទនៅពេលនេះ បានឆ្លើយទទួលស្គាល់នូវអំពើប្រព្រឹត្តអស់ហើយ។ នៅពេលនេះខ្លួនសំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។

៨-មេធាវី [redacted] ស៊ីថាន់ ការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានថា នៅពេលនេះ ខ្លួនសុំឯកភាពតាមការបញ្ជាក់របស់មេធាវី ជា ណារ៉ា ទាំងស្រុង ។

៩-មេធាវី [redacted] វិមានចំប៉ា ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា នៅពេលសវនាការនេះ កូនក្ដីខ្លួនបានឆ្លើយសារភាពអស់ហើយ។ ក៏ប៉ុន្តែខ្លួនសុំបញ្ជាក់ថា កូនក្ដីខ្លួនអត់បានបង្ខិតបង្ខំជនរងគ្រោះអ្វីឡើយ គឺជនរងគ្រោះគាត់ស្មោះស្ម័គ្រដោយខ្លួនឯងម្យ៉ាងវិញទៀត អំពើដែលកូនក្ដីខ្លួនប្រព្រឹត្តនោះ គឺកូនក្ដីខ្លួនអត់បានយល់ដឹងថា ខុសច្បាប់យ៉ាងណានោះទេ។ ដូច្នេះ នៅពេលនេះខ្លួនសំណូមពរសុំសាលាឧទ្ធរណ៍មេត្តា បន្ធូរបន្ថយទោសឲ្យកូនក្ដីខ្លួនតាមច្បាប់ ។

១០-មានពិរុទ្ធភាពលើឈ្មោះ [redacted] ស្រីស និងឈ្មោះ [redacted] ស្រីជា ហៅ គាព ពីបទ: សញ្ជារកម្ម មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខភោជនីយដ្ឋានសេងលីប ផ្លូវព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩-៩-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨៨ នៃក្រមព្រហ្មទណ្ឌ ។

១១-រឿងក្តីនេះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេតនឹងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

១២-សាលក្រមព្រហ្មទណ្ឌលេខ:៨១"ក្រ.១.គ" ចុះថ្ងៃទី០២-៤-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណ:ត្រឹមត្រូវតាមអង្គហេតុនឹងគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-៤-២០១៣ របស់ឈ្មោះ [redacted] ស្រីជា និងឈ្មោះ [redacted] ស្រីស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៨១"ក្រ.១.គ" ចុះថ្ងៃទី០២-៤-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ស្រីស និងឈ្មោះ [redacted] ស្រីជា ។

៤-សាលដីកានេះ ប្រកាសជាសាធារណ: នៅថ្ងៃទី២០-១០-២០១៤ ចំពោះមុខជនជាប់ចោទទាំងពីរ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិឲ្យប្តឹងសាទុក្ខ និងតវ៉ាតាមកំណត់ច្បាប់ ។ /W/-

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ភ្នំពេញ, ថ្ងៃទី 24 ខែ 12 ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]